# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ: ៧៩ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពី
## ការបង្កើតគណៈកម្មាធិការជាតិបណ្តុះបណ្តាល

*****

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១.-**

បង្កើតគណៈកម្មាធិការជាតិបណ្តុះបណ្តាល ដែលហៅកាត់ថា "គ.ជ.ប.ប" ដើម្បីសម្របសម្រួលជាមួយក្រសួង ស្ថាប័ន អង្គការនានាដែលពាក់ព័ន្ធ ដើម្បីអភិវឌ្ឍប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ អោយឆ្លើយតបទៅនឹង សេចក្តីត្រូវការរបស់សង្គមសេដ្ឋកិច្ចបច្ចុប្បន្ន និងទៅអនាគតនៅកម្ពុជា។

**មាត្រា ២.-**

- សមាសភាពនៃគណៈកម្មាធិការជាតិបណ្តុះបណ្តាលមានដូចខាងក្រោម :

| | | |
|---|---|---|
| ១. ឯកឧត្តម **សុខ អាន** | ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | ប្រធាន |
| ២. ឯកឧត្តម **ពេជ សោភ័ន** | រដ្ឋលេខាធិការ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | អនុប្រធាន |
| ៣. ឯកឧត្តម **សយ ស៊ីផុន** | រដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | អនុប្រធាន |
| ៤. ឯកឧត្តម **ម៉ក់ វ៉ាន់** | រដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា | អនុប្រធាន |
| ៥. លោក **វ៉ាន់ ស៊ុនអៀង** | ប្រធានសហព័ន្ធនិយោជក និងសមាគមពាណិជ្ជកម្មកម្ពុជា | អនុប្រធាន |
| ៦. ឯកឧត្តម **ឡា ណាវ៉ាត** | រដ្ឋលេខាធិការ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |

| | | |
|---|---|---|
| ៧. ឯកឧត្តម **សំ ព្រាហ្មនា** | រដ្ឋលេខាធិការ ក្រសួងទេសចរណ៍ | សមាជិក |
| ៨. ឯកឧត្តម **ម៉ែន ហាន** | រដ្ឋលេខាធិការ ក្រសួងផែនការ | សមាជិក |
| ៩.ឯកឧត្តម **ទ៊ា ជាង** | អនុរដ្ឋលេខាធិការ ក្រសួងពាណិជ្ជកម្ម | សមាជិក |
| ១០.ឯកឧត្តម **នូ មុត** | អនុរដ្ឋលេខាធិការ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១១.ឯកឧត្តម **ស្ងួត សំបូរ** | អគ្គនាយករដ្ឋបាល ក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ១២. ឯកឧត្តម **ជួប សំអាត** | អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ ក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ១៣. លោកជំទាវ **ជូ ប៊ុនអេង** | អគ្គនាយកអភិវឌ្ឍន៍សង្គម ក្រសួងកិច្ចការនារី | សមាជិក |
| ១៤. ឯកឧត្តម **លាភ វណ្ណដេន** | អគ្គលេខាធិការរង គណៈកម្មាធិការនីតិសម្បទា និងការអភិវឌ្ឍន៍ / ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ១៥. ឯកឧត្តមបណ្ឌិត **អ៊ឹ សុផល** | សកលវិទ្យាធិការនៃសកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល ក្រសួងសុខាភិបាល | សមាជិក |
| ១៦. បណ្ឌិត **ហ៊ាន សាហ៊ីប** | អគ្គលេខាធិការរង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១៧. លោក **ព្រាំ សំអ៊ាន** | អគ្គនាយករងរដ្ឋបាល និងហិរញ្ញវត្ថុ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ១៨. លោក **អ៊ុច បូរ៉ា** | អគ្គនាយករងនៃអគ្គនាយកដ្ឋានធនធានរ៉ែ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |
| ១៩. លោក **សំ ខាន់ឌី** | អគ្គនាយករងបច្ចេកទេស ក្រសួងបរិស្ថាន | សមាជិក |
| ២០. លោកឧកញ៉ា **ណាង សុធី** | អគ្គនាយក សភាពាណិជ្ជកម្មកម្ពុជា | សមាជិក |
| ២១.លោក **តាន់ មុនីវណ្ណ** | អគ្គនាយករង ក្រុមហ៊ុន ម៉ុង ឬទ្ធីគ្រុប ជាតំណាងនិយោជក | សមាជិក |
| ២២. លោក **ខេង លូ** | តំណាងវិស័យឧស្សាហកម្មកាត់ដេរ ជាតំណាងនិយោជក | សមាជិក |
| ២៣. លោក **សុខ ខេង** | តំណាងវិស័យឧស្សាហកម្មសណ្ឋាគារ ជាតំណាងនិយោជក | សមាជិក |
| ២៤ លោក **ជួន មុំ ថុល** | ប្រធានសហភាពសហព័ន្ធសហជីពជាតិកម្ពុជា ជាតំណាងនិយោជិត | សមាជិក |
| ២៥. លោក **រស់ សុភ** | អនុប្រធានទី ១ សហភាពសហព័ន្ធសហជីពជាតិកម្ពុជា ជាតំណាងនិយោជិត | សមាជិក |
| ២៦. ឯកឧត្តម **ប៊ុន ភារិន** | នាយកវិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា តំណាងអ្នកផ្តល់ការបណ្តុះបណ្តាល | សមាជិក |
| ២៧. លោក **ជុន ណាទី** | គ្រូបង្រៀន និងជំនួយការនាយក តំណាងអ្នកផ្តល់ការបណ្តុះបណ្តាល | សមាជិក |
| ២៨. លោកស្រី **ដួង វ៉ាន់ឆេត** | នាយិកាមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តបាត់ដំបង តំណាងអ្នកផ្តល់ការបណ្តុះបណ្តាល | សមាជិក |
| ២៩.ឯកឧត្តម **ឡៅ ហ៊ីម** | អគ្គនាយកអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | នាយកប្រតិបត្តិ |

- គណៈកម្មាធិការជាតិអាចអញ្ជើញតំណាង ៣រូប របស់អង្គការអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាល ចូលរួមបាន។
- គណៈកម្មាធិការជាតិនេះមាន អគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជាលេខាធិការដ្ឋានអចិន្ត្រៃយ៍ ។

មាត្រា ៣.-

គណៈកម្មាធិការជាតិនេះមានភារកិច្ច :

- រៀបចំគោលនយោបាយ និងគំរោងផែនការជាតិ សំរាប់អប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ។
- សម្របសម្រួល និងតំរង់ទិសការងារអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ដើម្បីឆ្លើយតបទៅនឹងតំរូវការនៃការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ ក្នុងពេលបច្ចុប្បន្ន និងទៅអនាគត ។
- លើកគំរោងកែទំរង់ និងអភិវឌ្ឍប្រព័ន្ធអប់រំនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីអោយក្លាយជាប្រព័ន្ធមួយដែល :
  - មានគុណភាព និងប្រសិទ្ធភាពខ្ពស់
  - ផ្សារភ្ជាប់ទៅនឹងអាទិភាពនៃការអភិវឌ្ឍន៍ជាតិ
  - ឆ្លើយតបទៅនឹងតម្រូវការរបស់ឧស្សាហកម្ម ពាណិជ្ជកម្ម កសិកម្ម សេវាកម្ម ។ល។
  - មានទំនាក់ទំនងរវាងកន្លែងធ្វើការងារ និងគ្រឹះស្ថានបណ្តុះបណ្តាល

មាត្រា ៤.-

- គណៈកម្មាធិការជាតិ ត្រូវជ្រើសតាំងសមាជិករបស់ខ្លួន ៩រូប ធ្វើជាគណៈកម្មការប្រតិបត្តិ ដែលមានសមាសភាព ដូចខាងក្រោម :

| | |
|---|---|
| - ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | ប្រធាន |
| - តំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | អនុប្រធាន |
| - តំណាង ២រូប របស់ក្រសួង ឬ ស្ថាប័នរាជរដ្ឋាភិបាល | សមាជិក |
| - តំណាង ២រូប របស់និយោជក | - |
| - តំណាង ១រូប របស់និយោជិត | - |
| - តំណាង ១រូប របស់អ្នកផ្តល់ការបណ្តុះបណ្តាល ✓ | - |

- គណៈកម្មការប្រតិបត្តិអាចអញ្ជើញតំណាង ១រូប របស់អង្គការអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាលចូលរួម ។
- គណៈកម្មការប្រតិបត្តិនេះមាននាយកប្រតិបត្តិធ្វើជាលេខាអចិន្ត្រៃយ៍ ។

មាត្រា ៥.-

គណៈកម្មការប្រតិបត្តិនេះមានភារកិច្ច :

- គ្រប់គ្រងក្នុងនាមគណៈកម្មាធិការជាតិ នូវមូលនិធិជាតិបណ្តុះបណ្តាល ។
- រៀបចំកម្មវិធី និងរបៀបវារៈប្រជុំ របស់គណៈកម្មាធិការជាតិ ។
- លើកសំណើដែលពាក់ព័ន្ធដល់ការងារអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ជូនគណៈកម្មាធិការជាតិ ពិនិត្យ និងសំរេច ។

មាត្រា ៦.-

នៅតាមខេត្ត-ក្រុង ត្រូវបង្កើតអោយមានគណៈកម្មាធិការសម្របសម្រួលការងារអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ

ថ្នាក់ខេត្ត-ក្រុង ដែលហៅកាត់ថា គណៈកម្មាធិការខេត្ត-ក្រុងបណ្តុះបណ្តាល ។ សមាសភាពគណៈកម្មាធិការនេះរួមមាន ៖ អភិបាលខេត្ត-ក្រុង ជាប្រធាន ប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជាអនុប្រធាន ប្រធានមន្ទីរពាក់ព័ន្ធ តំណាងអង្គការអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាល តំណាងនិយោជក តំណាងនិយោជិត និងតំណាងអ្នកផ្តល់ការបណ្តុះបណ្តាល ជាសមាជិក ហើយមានការិយាល័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈរបស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត-ក្រុង ជាលេខាធិការដ្ឋាន ។

**មាត្រា ៧.-**

ភារកិច្ចរបស់គណៈកម្មាធិការខេត្ត-ក្រុងបណ្តុះបណ្តាល ត្រូវកំណត់ក្នុងលក្ខន្តិកៈដោយគណៈកម្មាធិការជាតិបណ្តុះបណ្តាល ។

**មាត្រា ៨.-**

គណៈកម្មាធិការជាតិបណ្តុះបណ្តាលមានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

**មាត្រា ៩.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១០.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ អភិបាលខេត្ត-ក្រុង គណៈកម្មាធិការជាតិបណ្តុះបណ្តាល និងបណ្តាសមាសភាពដូចមានចែងក្នុងមាត្រា ២ មាត្រា ៤ មានភារកិច្ចអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ ១១ ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល៖**

ក្រសួងព្រះបរមរាជវាំង
អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សារដ្ឋធម្មនុញ្ញ
អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
អគ្គលេខាធិការដ្ឋានរដ្ឋសភា
ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
អគ្គលេខាធិការរាជរដ្ឋាភិបាល
ដូចមាត្រា ២ -មាត្រា ៤ -មាត្រា ១០
ឯកសារ-កាលប្បវត្តិ